## ៨. សន្និដ្ឋាន

យោងលើលទ្ធផលនៃវាយតំលៃហេតុប៉ះពាល់បរិស្ថាននិងសង្គម នៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ច ដែលស្នើសុំដោយក្រុមហ៊ុន **C.R.C.K.2 APHIVATH CAOUT CAOUC CO., LTD.**រួចមក ក្រុមការងារបាន ធ្វើការសន្និដ្ឋានដូចខាងក្រោមៈ

**២២៤.** ជាទូទៅវាយនភាពដីនៅតំបន់សម្បទាននេះមានមានសិលាមេ៣ប្រភេទគឺ: (១)Floodplains (១២ហិកតា)ស្មើនឹង ០,១៦ភាគរយ (២) Lake bed deposits (៧ហិកតា) ស្មើនឹង០,០៩ ភាគរយ (៣) Peneplain laterite deposits (៧២៧០ហិកតា) ស្មើនឹង៩៩,៧៥ ភាគរយនៃផ្ទៃដីសរុប ។

**២២៥.** នៅតំបន់ដីសម្បទាននេះសំបូរប្រភពទឹកស្រទាប់លើ ដែលមានអូរពពកនៅខាងលិចទៅកើត និងពីត្បូងទៅជើង ដូចជាអូរក្រសាំង អូរដំបូកជ្រាប ត្រពាំងអរជូន ត្រពាំងឡប....។ល។ ហូរពីក្នុងចេញទៅខាងក្រៅកាត់តំបន់ដីសម្បទានធ្លាក់ចូលទៅក្នុង ស្ទឹងស្ទោង ក្នុងកំឡុងរដូវធ្លាក់ភ្លៀង ដែលហូរពីតំបន់ទីជំរាលខ្ពស់មកទាបដល់ទន្លេសាប ហើយបច្ចុប្បន្នទឹកស្រទាប់លើពុំទាន់មានការទទួលរងនូវការបំពុលពីផ្នែកឧស្សាហកម្មនៅឡើយ ។

**២២៦.** តាមរយៈរូបភាព Photo Index Maps នៅលើចំណុចទាំង១០ (Photo Index A, B, C, D, E, F, G, H, I, J, ) បង្ហាញអោយឃើញថា គំរបព្រៃនិងធនធានព្រៃឈើមានលក្ខណៈជាព្រៃស្រោងដែលទទួលរងការរំខានធ្ងន់ធ្ងរ ឬអាចយល់បានថាជាព្រៃពាក់កណ្តាលស្រោងរេចរិល ចំណែកឯដីដែល គ្មានព្រៃគឺជាដីដែលប្រជាពលរដ្ឋក្នុងតំបន់ធ្វើការរានកាប់ឆ្ការដើម្បីដាំដំណាំ និងដីដែលក្រុមហ៊ុនទើបតែធ្វើការឈូសឆាយ ហើយកាលពីរដូវប្រាំងកន្លងទៅនេះ។ ព្រៃដែលមាននៅសេសសល់ក្នុងតំបន់នេះ ស្ទើរតែបាត់បង់តម្លៃពាណិជ្ជកម្មទាំងស្រុងហើយ ។

**២២៧.** ការសិក្សាទៅលើរូបភាពនេត្រាទស្សន៍-១ អំពីស្ថានភាពនៃការប្រើប្រាស់ដីក្នុងតំបន់ដីសម្បទាន បង្ហាញថា ព្រៃឈើទាំងនេះមានលក្ខណៈជាព្រៃចំរុះ ស្ថានភាពគំរបព្រៃមានលក្ខណៈបង្គួរ និងមានការរំខានពីការកាប់រានធ្វើចំការរបស់ប្រជាជននៅរួចទៅហើយ ។ ចំពោះរូបភាពនេត្រាទស្សន៍-២ សង្កេតឃើញ មានដីវាលដែលបានកាប់ឈូសឆាយដោយក្រុមហ៊ុន ដើម្បីដាំដំណាំកៅស៊ូនៅក្នុងតំបន់នោះ ហើយក៏ឃើញមានសំណាកចំការចាស់ផងដែរ (ជាចំការបុស្ស) របស់ប្រជាជនក្នុងមូលដ្ឋាន។ តាមការជួបសន្ទនាជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋក្នុងតំបន់នោះ បានអោយដឹងថា នៅក្នុងតំបន់ដូចបានរៀបរាប់ខាងលើនេះពិតជាមានដីចំការចន្ទីនិងដីស្រែចំការចាស់របស់ពួកគាត់មែន តែត្រូវបានក្រុមហ៊ុនដោះស្រាយឱ្យរួចហើយ តែនៅមានសេសសល់តិចតួចតាមមាត់អូរ ដែលក្រុមហ៊ុននឹងត្រូវដោះស្រាយបន្ត ។

Draft

**២២៨.** នៅក្នុងប្រភេទព្រៃស្រោងរបស់តំបន់សម្បទាន មានរុក្ខជាតិចំនួន ៩៨ប្រភេទ ជុល្លិព្រឹក្ស៥៥ប្រភេទ និងតិណជាតិចំនួន៦៨ប្រភេទ។ ភាពសម្បូរណ៏បែប និងសមាសភាពនៃរុក្ខជាតិ ទាំងនោះត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយ ក្នុងការពន្យល់បកស្រាយពីរចនាសម្ព័ន្ធទីជំរកដោយលោក Scweithelm and Chhay 2007 ដោយបាន និយាយថា នៅក្នុងព្រៃល្បោះ គ្របដណ្តប់ដោយប្រភេទរុក្ខជាតិ ដូចជា ខ្លុង ត្បែង ផ្ចិក រាំងភ្នំ នាងផ្អែក ក្នុងពេលដែលពពួកស្បូវ និងស្មៅព្រិច ជាពពួករុក្ខជាតិថ្នាក់ក្រោម។ ចំណែកឯនៅក្នុងព្រៃពាក់កណ្តាលស្រោងវិញសម្បូរណ៏ទៅដោយ *Lagerstroemia cochinchinesis*, *Xylia xylocarpa*, *Cratoxylum conchinchinense*, and *Shorea siamensis*, *Irivingia malayana* and that understory *Arundinaria pusilla* and *Bambusa bambos* ។

**២២៩.** ការសិក្សាបានបង្ហាញថា មានសត្វស្លាបចំនួន ភាពសំបូរបែបនៃសត្វស្លាបដែលបានកត់ត្រានៅក្នុងតំបន់សិក្សាស្រាវជ្រាវ គឺមានចំនួនស្មើនឹង ៦៤ភាគរយ នៃលទ្ធផលដែលទទួលបានពីការសំភាសន៍ជាមួយប្រជាជនមូលដ្ឋាន រស់ក្បែរតំបន់ស្រាវជ្រាវ និងត្រូវជា ០៦ភាគរយ នៃចំនួនសត្វស្លាបសរុបក្នុងប្រទេសកម្ពុជា។ ចំណែកឯមានថនិកសត្វចំនួន ០៦ប្រភេទដែលជួបប្រទះ នៅក្នុងតំបន់ដីគំរោងវិនិយោគ ហើយថនិកសត្វដែលកត់ត្រាបានមានចំនួនប្រមាណ២៨,៥៧ភាគរយ នៃចំនួនសត្វដែលបានពីការសំភាសន៍ប្រជាជនមូលដ្ឋាន ហើយត្រូវជា ២,៧៥ភាគរយ នៃចំនួនថនិកសត្វសរុបនៅក្នុងប្រទេសកម្ពុជា។ ចំពោះមច្ឆាជាតិវិញ នៅក្នុងតំបន់សម្បទាននេះមិនសំបូរប្រភពទឹកស្រទាប់លើទេ ក្រៅពីអូរតូច២ពីរគឺ អូរដូងត្រាច និង អូរកោសលង់ មានតែត្រពាំងចំនួន ០៥ដែលរីងនៅចុងរដូវប្រាំង។ តាមការសាកសួរពីប្រជាជនមូលដ្ឋាន បញ្ជាក់ថា ពួកគាត់ធ្លាប់នេសាទបាននូវប្រភេទត្រីមួយចំនួន (ទាំងប្រភេទត្រីស និងត្រីខ្មៅ) នៅក្នុងតំបន់នោះគឺ ត្រីឆ្ពិន ត្រីចង្វារជញ្ជាត់ដៃ ត្រីស្រកាក្តាម ត្រីក្រោស...។

**២៣០.** ផលិតផលចំការស្វាយចន្ទី ជាប្រភពចំណូលសំខាន់របស់គ្រួសារនីមួយ១។ តែផ្ទៃដីសំរាប់ធ្វើស្រែមានតិចតួចមិនអាចផ្តល់ឱ្យគ្រប់គ្រួសារឡើយ គ្រួសារដែលគ្មានដីស្រែបានទៅរានដីធ្វើចំការទៅតាមលទ្ធភាពរៀង១ខ្លួន។ គ្រួសារភាគច្រើនដាំស្វាយចន្ទី ទិន្នផលនៃមុខដំណាំនេះអាចធ្វើឱ្យប្រជាជននៅក្នុងតំបន់នេះមានជីវភាពធូរធារមួយកំរិត ក្នុងរយៈពេលពីឆ្នាំមុននេះ(២០០៩) ដែលតំលៃក្នុង១គីឡូក្រាមលក់បានក្នុងតំលៃ ២៥០០-៣០០០រៀល។ ក្រៅពីនោះពួកគាត់ប្រកបរបរកាប់អុស និងកាប់ឈើនៅក្នុងតំបន់អភិរក្ស។ ចំណូលដែលបានមកពីការធ្វើចំការ និងចំការស្វាយ ចន្ទីនេះក៏នៅតែមិនអាចទ្រទ្រង់នូវជីវភាពក្នុងគ្រួសាររបស់ ពួកគាត់ល្អទេ ព្រោះគ្រួសារភាគច្រើនមានសមាជិកច្រើន ហើយការដាំដំណាំចន្ទីរបស់ពួកគាត់មានលក្ខណៈជាយថាផល ចំណែកឯទិន្នផលស្រូវដែលទទួលបាន នៅមានកំរិតទាបនៅឡើយគិតជាមធ្យមគឺ១-១.៥ តោន ក្នុង១ឆ្នាំមួយហិកតាចំពោះស្វាយចន្ទីមាន៥០០-៧០០ដើម/ហិកតា) ដូចនេះមួយឆ្នាំអាចទទួលបានប្រមាណ២.៥០០.០០០-៣.១៥០.០០០រៀល។

Draft

**២៣១.** សេដ្ឋកិច្ចក្នុងតំបន់មានលក្ខណៈជាសេដ្ឋកិច្ចជនបទ លើកលែងតែទីរួមខេត្តចេញ ដែលការប្រកបរបរមានទ្រង់ទ្រាយពាណិជ្ជកម្ម។ ចំណូលប្រចាំឆ្នាំរបស់គ្រួសារក្នុងសហគមន៍មានលក្ខណៈផ្សេងៗគ្នាអាស្រ័យទៅនឹងការប្រកបមុខរបររបស់គ្រួសារនីមួយៗ។ ការវាយតំលៃអំពីភាពក្រីក្របានបង្ហាញថា អាត្រានៃភាពក្រីក្រនៅក្នុងខេត្តកំពង់ធំមានៈ ២៩.១០ភាគរយ (១៥៨.៩០ភាគពាន់) លើចំនួនប្រជាជនសរុប ៦២៤.៨៤៦នាក់ ក្នុងនោះមាន ៦២១.៨៣៣នាក់ ឬស្មើនឹង ៩៩ភាគរយ រស់នៅជនបទ (ផែនទីភាពក្រីក្ររបស់កម្មវិធីស្បៀងអង្គការសហប្រជាជាតិឆ្នាំ២០០៥-២០០៦ និងប្រព័ន្ធទិន្នន័យសហគមន៍ឆ្នាំ២០០៤)។

**២៣២.** លទ្ធភាពនៃការប្រើប្រាស់សេវាសាធារណៈមាន : គមនាគមន៍ ការផ្គត់ផ្គង់ទឹកស្អាត អគ្គិសនី អប់រំ និងសុខាភិបាល) នៅក្នុងសហគន៍ដាច់ស្រយាលទាំងនេះស្ថិតនៅក្រោមបន្ទាត់នៃតម្រូវការ បើប្រៀបធៀបជាមួយនឹងគ្រួសារសហគមន៍នៅក្នុងតំបន់ដទៃទៀតរបស់ប្រទេសកម្ពុជា។ ការសិក្សាបានបង្ហាញ ឱ្យឃើញថាអ្នកភូមិដែលរស់នៅតាមដងផ្លូវក៏ដូចជាប្រជាជនដែលរស់នៅតាមភូមិក្នុងឃុំពពកដែរ ពុំបានទទួលការផ្គត់ផ្គង់អគ្គិសនីជាមូលដ្ឋានទេ។ មានគ្រួសារតិចតួចណាស់ដែលប្រើអាគុយខណៈដែលមួយចំនួនធំបានប្រើប្រាស់ចន្លុះសំរាប់បំភ្លឺនៅពេលយប់។ រីឯប្រភពថាមពលសំខាន់សំរាប់ការចំអិនអាហាររបស់ពួកគាត់ គឺអុស ដែលអាចរកបានពីព្រៃដែលនៅមិនឆ្ងាយពីលំនៅដ្ឋានរបស់ពួកគាត់។

**២៣៣.** ការធ្វើដំណើរ និងដឹកជញ្ជូននៅក្នុងតំបន់គំរោងភាគច្រើនគឺប្រើប្រាស់ផ្លូវជាតិលេខ៦ (ភ្នំពេញ-កំពង់ធំ) និង(កំពង់ធំ-ស្ទោង)រីឯផ្លូវដែលតភ្ជាប់ផ្លូវជាតិទៅនឹងសហគមន៍ពួកគាត់ ជាផ្លូវលំក្រាលគ្រួសក្រហមដែលជាអំណោយរបស់ ឯកឧត្តមងួន ញ៉ិល ហើយផ្លូវមួយចំនួនទៀតជាផ្លូវរទេះ ឬផ្លូវលំដើរដោយជើង។ ផ្លូវទាំងនេះនៅក្នុងរដូវវស្សាមានសភាពលំបាកធ្វើដំណើរ តែមានភាពងាយស្រួលជាង២-៣ឆ្នាំមុន។ ដោយសារ តែការធ្វើដំណើរចេញចូលមានលក្ខណៈល្អប្រសើរ ដូច្នេះហើយទើបធ្វើឱ្យការប្រាស្រ័យទាក់ទងរវាងសហគមន៍ទាំងនេះជាមួយនឹងតំបន់ខាងក្រៅមានលក្ខណៈទូលំទូលាយ និងទទួលបានការយកចិត្តទុកដាក់តិចតួចពីបណ្តាភ្នាក់ងារអភិវឌ្ឍន៍ផ្សេងៗ ដែលក្នុងនោះមានការផ្គត់ផ្គង់ទឹកស្អាត និងសាលារៀន ជាដើម ។

Draft

## ៩. អនុសាសន៍

យោងលើសេចក្តីសន្និដ្ឋានស្តីពីហេតុប៉ះពាល់បរិស្ថាននិងសង្គម ក្រុមការងារសូមផ្តល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោម:

២៣៤. នៅក្នុងដំណើរប្រតិបត្តិការគំរោងសាម៉ីវិនិយោគិន ត្រូវតែអនុវត្តផែនការគ្រប់គ្រងបរិស្ថានទៅតាមវិធានការណ៍នានាដូចមានកំណត់នៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងផែនការគ្រប់គ្រងបរិស្ថាន ដូចបានពណ៌នានៅក្នុងតារាង ៦-១ និងតារាង៦-៣ នោះស្ថាប័នជំនាញ និងអាជ្ញាធរពាក់ព័ន្ធ ត្រូវតាមដានពិនិត្យនិងវាយតំលៃទៅលើសកម្មភាពនៃការអភិវឌ្ឍន៍របស់វិនិយោគិន ជាប្រចាំទៅតាមកម្មវិធីដូចមានកំណត់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន។

ភ្នំពេញ, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០

**នាយក**

ហត្ថលេខា និងត្រា

Green Consultancy Firm

KINGDOM OF CAMBODIA

បណ្ឌិត. លី_សុពណ៌_មុនី

ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០១០

**នាយកក្រុមហ៊ុន**

ហត្ថលេខា និងត្រា

Draft